


# ជម្រើសនានាសម្រាប់សិស្សានុសិស្សដែលមិនបានបញ្ចប់ការសិក្សា បន្ទាប់ពីរៀននៅមធ្យមសិក្សារយៈពេលបួនឆ្នាំ

សិស្សានុសិស្សដែលមិនបានបំពេញតាមការតម្រូវការនៃការបញ្ចប់ ការសិក្សាពីថ្នាក់មធ្យមសិក្សា **ហើយ**មិនទទួលបានសញ្ញាប័ត្រមធ្យមសិក្សាតាមធម្មតាគឺមានសិទ្ធិទទួលបានការអប់រំជាសាធារណៈ ដោយឥតគិតថ្លៃពេញមួយឆ្នាំសិក្សា ដែលពួកគេមានអាយុឡើងដល់ 21 ឆ្នាំ។ ករណីនេះរាប់បញ្ចូលទាំងសិស្សានុសិស្សអាយុតិចជាង 21 ឆ្នាំ ដែលទទួលបានវិញ្ញាបណប័ត្រដែលមានតម្លៃស្មើនឹងមធ្យមសិក្សា ឬដែលបានចុះឈ្មោះនៅក្នុង:

- កម្មវិធីអប់រំអាជីព និងបច្ចេកទេស ដោយរួមមានមជ្ឈមណ្ឌលជំនាញនានា
- កម្មវិធីអប់រំអន្តរទ្វេភាសា
- កម្មវិធីអប់រំពិសេស ឬ
- កម្មវិធីអប់រំការជនអន្តោប្រវេសន៍។

សាលាមធ្យមសិក្សា និងមណ្ឌលសិក្សានៅបន្តទទួលការផ្តល់ការអប់រំមូលដ្ឋានដោយឡែក (BEA) និងការផ្តល់ប្រាក់ជំនួយណាមួយដែលសិស្សានុសិស្សទាំងនេះធ្វើឲ្យមាន។

## ជម្រើសឥតគិតថ្លៃ

ជម្រើសឥតគិតគឺអាចមានសម្រាប់សិស្សានុសិស្ស ដែល**មិន**បានបញ្ចប់ការសិក្សា បន្ទាប់ពីរៀននៅមធ្យមសិក្សារយៈបួនឆ្នាំ និងចង់បំពេញតាមតម្រូវការនៃការបញ្ចប់ការសិក្សាពីមធ្យមសិក្សារបស់ពួកគេ។ ជម្រើសទាំងអស់គឺ:

1. **ការចុះឈ្មោះបន្តការសិក្សានៅមធ្យមសិក្សា:** គ្រប់សិស្សានុសិស្សទាំងអស់មានសិទ្ធិទទួលបានការសិក្សានៅមធ្យមសិក្សាក្នុងស្រុករបស់ពួកគេពេញមួយឆ្នាំសិក្សា ដែលពួកគេមានអាយុឡើងដល់ 21 ឆ្នាំ។
2. **ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីបញ្ចប់ការសិក្សានៅមធ្យមសិក្សានៃមណ្ឌលសិក្សា:** មណ្ឌលសិក្សាអាចធ្វើកិច្ចសន្យាជាមួយនឹងមហាវិទ្យាល័យសហគមន៍ ដើម្បីផ្តល់កម្មវិធីបំពេញមធ្យមសិក្សាដោយឥតបង់ថ្លៃសាលាចំពោះសិស្សានុសិស្សដែលនៅកំពុងរៀនក្នុងមណ្ឌសិក្សាក្នុងស្រុករបស់ពួកគេ។ នៅពេលបញ្ចប់កម្មវិធី សិស្សានុសិស្សទទួលបានសញ្ញាប័ត្រមធ្យមសិក្សាពីមណ្ឌលសិក្សានោះ។
3. **ចាប់ផ្តើមដំណើរការបន្ត:** សិស្សានុសិស្សដែលបានចូលរួមក្នុងកម្មវិធីចាប់ផ្តើមដំណើរនៅកំឡុងឆ្នាំសិក្សាថ្នាក់ទី 11 និង 12 របស់ពួកគេ ប៉ុន្តែមិនបានបំពេញតាមតម្រូវការតាមថ្នាក់នីមួយៗ សម្រាប់ការបញ្ចប់មធ្យមសិក្សាអាចបន្តការចូលរួមក្នុងកម្មវិធីចាប់ផ្តើមដំណើរ ប៉ុន្តែត្រូវតែរៀនយកថ្នាក់ទាំងនោះប៉ុណ្ណោះ តាមរយៈកម្មវិធីចាប់ផ្តើមដំណើរដែលពួកគេប្រឡងធ្លាក់ ឬមិនបានបំពេញ និងត្រូវការទទួលបានសញ្ញាប័ត្រមធ្យមសិក្សា។ (កម្មវិធីចាប់ផ្តើមដំណើរបន្តអនុញ្ញាតឲ្យសិស្សានុសិស្ស ថ្នាក់ទី 11 និង 12 ដែលមានសិទ្ធិរៀននៅមហាវិទ្យាល័យដោយឥតបង់ថ្លៃសាលា ហើយនិងបង្កើនបានក្រេឌីតទាំងនៅមធ្យមសិក្សានិងនៅមហាវិទ្យាល័យសម្រាប់ថ្នាក់ទាំងនោះ។)
4. **ការចូលរួមឡើងវិញរបស់យុវជន [1418] បើកទូលាយទ្វារ:** កម្មវិធីដែលដំណើរការដោយមណ្ឌលសិក្សា ឬភាពជាដៃគូរវាងមណ្ឌលសិក្សា និងមហាវិទ្យាល័យ ESD ឬសហគមន៍ ដែលមានមូលដ្ឋានមកពីអង្គការដែលផ្តល់:
   - ការណែនាំនៃការសិក្សា ដោយរួមមានការរៀបចំឲ្យមានវិញ្ញាបនបត្រដែលមានតម្លៃស្មើនឹងមធ្យមសិក្សា ការសិក្សាជំនាញ និងមហាវិទ្យាល័យ និងការរៀបចំត្រៀមធ្វើការ ដែលធ្វើឲ្យមានក្រេឌីតនៅមធ្យមសិក្សាសម្រាប់យកសញ្ញាប័ត្រ និងមានគោលដៅនៃការសិក្សា និងការត្រៀមធ្វើការ។
   - ការណែនាំដោយគ្រូបង្រៀនដែលមានវិញ្ញាបនបត្រ ឬសាស្ត្រាចារ្យមហាវិទ្យាល័យ ដែលការសម្ភាត់របស់ខ្លួនត្រូវបានបង្កើតឡើងដោយមហាវិទ្យាល័យ។
   - ការគ្រប់គ្រងសំណុំរឿង សេវាផ្តល់ប្រឹក្សា និងធនធាន និងសេវាបញ្ជូន។
   - ឱកាសសំរាប់សិស្សានុសិស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រងក្នុងការចុះឈ្មោះរៀននៅមហាវិទ្យាល័យដោយឥតបង់ថ្លៃសាលា ប្រសិនបើអ្នកផ្តល់កម្មវិធីនេះគឺជាមហាវិទ្យាល័យ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនា **www.k12.wa.us/GATE/SupportingStudents/StudentRetrieval.aspx**

(បន្ត)

សិស្សានុសិស្សដែលមិនបានបញ្ចប់ការសិក្សា បន្ទាប់ពីរៀននៅមធ្យមសិក្សារយៈពេលបួនឆ្នាំក៏អាចមានជម្រើសគិតថ្លៃដែរ ប្រសិនបើពួកគេជ្រើសរើសមិនត្រឡប់ទៅរៀននៅមធ្យមសិក្សាវិញ។

## ជម្រើសគិតថ្លៃ

ជម្រើសគិតថ្លៃអាចមានសម្រាប់សិស្សានុសិស្ស ដែល**មិន**បានបញ្ចប់ការសិក្សា បន្ទាប់ពីរៀននៅមធ្យមសិក្សារយៈពេលបួនឆ្នាំ ហើយចង់បំពេញតាមការតម្រូវការនៃការបញ្ចប់មធ្យមសិក្សា។ ជម្រើសទាំងអស់គឺ:

1. **ចុះឈ្មោះក្នុងកម្មវិធីការបំពេញថ្នាក់មធ្យមសិក្សានៅមហាវិទ្យាល័យសហគមន៍ និងបច្ចេកទេស:** ចំនួននៃមហាវិទ្យាល័យសហគមន៍នៅក្នុងរដ្ឋបានផ្ដល់កម្មវិធីបំពេញថ្នាក់មធ្យមសិក្សាផ្ដល់ដល់សិស្សានុសិស្សនូវសញ្ញាប័ត្រមធ្យមសិក្សា*មកពីមហាវិទ្យាល័យ* ។ សិស្សានុសិស្សត្រូវតែឈប់ពីសាលាមធ្យមសិក្សាក្នុងមូលដ្ឋានរបស់ពួកគេ ដើម្បីចុះឈ្មោះនៅក្នុងកម្មវិធីទាំងនេះ។ ក្នុងស្ទើរតែគ្រប់ករណីទាំងអស់ សិស្សានុសិស្សត្រូវគិតថ្លៃសាលា និងថ្លៃឈ្នួលផ្សេងៗទៀតសម្រាប់ការចុះឈ្មោះ បើយ៉ាងណាជាមហាវិទ្យាល័យមានសិទ្ធិលើកលែងថ្លៃសាលា និងថ្លៃឈ្នួលសម្រាប់សិស្សានុសិស្សដែលមានអាយុ 19 ឆ្នាំឬចាស់ជាងនេះក៏ដោយ។ សិស្សានុសិស្សដែលមានអាយុ 16 ទៅ 18 ឆ្នាំ ត្រូវតែមានចុះហត្ថលេខាអនុញ្ញាឲ្យចេញពីសាលារៀននៅមណ្ឌលសិក្សារបស់ពួកគេ ដើម្បីចុះឈ្មោះក្នុងកម្មវិធីបំពេញថ្នាក់មធ្យមសិក្សានៅមហាវិទ្យាល័យសហគមន៍។

2. **បន្តស្វែងរកវិញ្ញាបនប័ត្រដែលមានតម្លៃស្មើនឹងមធ្យមសិក្សា:** សិស្សានុសិស្ស ដែលមានអាយុ16 និងចាស់ជាងអាចទទួលបានវិញ្ញាបនប័ត្រដែលមានតម្លៃស្មើនឹងមធ្យមសិក្សា ដោយការប្រឡងជាប់នូវការធ្វើតេស្តនានាដែលបានតម្រូវនានាតាមរយៈកម្មវិធីបំពេញថ្នាក់មធ្យមសិក្សា។ ដើម្បីធ្វើតេស្តសិស្សានុសិស្សត្រូវឈប់ ឬចេញពីថ្នាក់មធ្យមសិក្សាក្នុងមូលដ្ឋានរបស់ពួកគេ។ មហាវិទ្យាល័យសហគមន៍រដ្ឋ និងបច្ចេកទេសគឺជាមជ្ឈមណ្ឌលធ្វើតេស្តផ្លូវការសម្រាប់ វិញ្ញាបនប័ត្រដែលមានតម្លៃស្មើនឹងថ្នាក់មធ្យមសិក្សា។ សិស្សានុសិស្សបង់ឈ្នួលត្រូវបង់ថ្លៃសម្រាប់ការវាយតម្លៃ (នានា) ហើយអាចត្រូវតែបង់ថ្លៃសាលា និងថ្លៃថ្នាក់ត្រៀម ដែលបានផ្ដល់ឲ្យតាមរយៈមហាវិទ្យាល័យសហគមន៍ និងបច្ចេកទេស។ វិញ្ញាបនប័ត្រគឺមិនដូចជាសញ្ញាប័ត្រមធ្យមសិក្សាទេ ហើយសិស្សានុសិស្សដែលទទួលបានវិញ្ញាបនប័ត្រ ដែលមានតម្លៃស្មើនឹងមធ្យមសិក្សាអាចត្រូវបានចាត់ទុកថាបានបញ្ចប់ គោលបំណងទទួលខុសត្រូវរបស់ថ្នាក់មធ្យមសិក្សា។ ទោះជាយ៉ាងណា សិស្សានុសិស្សដែលមានអាយុតិចជាង 21 ឆ្នាំ ហើយដែលមានវិញ្ញាបនប័ត្រដែលមានតម្លៃស្មើនឹងថ្នាក់មធ្យមសិក្សាអាចនៅតែបំពេញតាមតម្រូវការនៃការបញ្ចប់ការសិក្សានៅមធ្យមសិក្សា និងទទួលបានសញ្ញាប័ត្ររបស់ពួកគេ។ (ចូរមើលជម្រើសឥតគិតថ្លៃនានា លេខ 1 និង 2 ខាងលើ។)

3. **ចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យ ឬសកលវិទ្យាល័យសាធារណៈរយៈពីរឆ្នាំ ឬបួនឆ្នាំ:** គ្មានមហាវិទ្យាល័យឬសកលវិទ្យាល័យសាធារណៈណាក្នុងរដ្ឋវ៉ាស៊ីងតោនតម្រូវឲ្យសិស្សានុសិស្សមានសញ្ញាប័ត្រមធ្យមសិក្សាដើម្បីទទួលបានការអនុញ្ញាតឲ្យចូលរៀននោះទេទោះបីជាសញ្ញាប័ត្រមធ្យមសិក្សាបង្កើន ឱកាសអនុញ្ញាតឲ្យចូលរៀននៅស្ថាប័នរយៈពេលបួនឆ្នាំរបស់រដ្ឋ គួរឲ្យកត់សម្គាល់។ សិស្សានុសិស្សដែលគ្មានសញ្ញាប័ត្រមធ្យមសិក្សា ដែលចុះឈ្មោះចូលរៀននៅ មហាវិទ្យាល័យ និងសកលវិទ្យាល័យត្រូវតែបង់ថ្លៃសាលា និងថ្លៃឈ្នួលផ្សេងៗទាំងស្រុងដូចសិស្សានុសិស្សដទៃទៀតទាំងអស់ដែរ។ សិស្សានុសិស្សដែលគ្មានសញ្ញាប័ត្រមធ្យមសិក្សា ឬវិញ្ញាបនប័ត្រដែលមានតម្លៃស្មើនឹងមធ្យមសិក្សា ប្រហែលជាមិនមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុរដ្ឋសហព័ន្ធ ឬឯកជនជាក់លាក់ណានោះទេ។